# អនុក្រឹត្យលេខ ២៦ អនក្រ.បក

## ស្តីពីការកាត់បន្ថយប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា ព្រមទាំងមន្ត្រីស៊ីវិល និងកងកម្លាំងប្រដាប់អាវុធចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៅតាមក្រសួង ស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន
- យោងសេចក្តីជូនដំណឹងតាមស្មារតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩

## សម្រេច

**មាត្រា ១ ._** អនុវត្តកាត់បន្ថយប្រាក់បំណាច់បន្ថែមលើបៀវត្សប្រចាំខែចំនួន ៧០% ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ១៩៩៩ តទៅ ចំពោះសមាជិក សមាជិការាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការនៃក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងទីប្រឹក្សានៃរាជរដ្ឋាភិបាល ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី ព្រមទាំងមន្ត្រីស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការឡើងទៅ ។

**មាត្រា ២ ._** ប្រាក់បំណាច់បន្ថែមលើបៀវត្សប្រចាំខែ ត្រូវកាត់បន្ថយចំនួន ៧០ % បានកំណត់ក្នុងតារាងដូចខាងក្រោម ៖

| ប្រភេទប្រាក់បំណាច់មុខតំណែង | ប្រាក់បំណាច់តំណាង | ប្រាក់បំណាច់បដិសណ្ឋារកិច្ច | ប្រាក់បំណាច់បេសកកម្ម | ប្រាក់ស្នួលផ្ទះ ទឹក ភ្លើង | សរុប |
|---|---|---|---|---|---|
| នាយករដ្ឋមន្ត្រី | ៣៤១.២៥០ | ២៨៨.៧៥០ | ១៨៣.៧៥០ | ២៨៨.៧៥០ | ១.១០២.៥០០ |
| ឧបនាយករដ្ឋមន្ត្រី | ២៧៥.៦២៥ | ២២៣.១២៥ | ១៤៤.៣៧៥ | ១៩៦.៨៧៥ | ៨៤០.០០០ |
| ទេសរដ្ឋមន្ត្រី | ២៤៩.៣៧៥ | ១៩៦.៨៧៥ | ១១៨.១២៥ | ១៧០.៦២៥ | ៧៣៥.០០០ |
| រដ្ឋមន្ត្រី | ២២៣.១២៥ | ១៧០.៦២៥ | ៩១.៨៧៥ | ១៤៤.៣៧៥ | ៦៣០.០០០ |
| រដ្ឋលេខាធិការ | ២១០.០០០ | ១៤៤.៣៧៥ | ៧៨.៧៥០ | ៩១.៨៧៥ | ៥២៥.០០០ |
| អនុរដ្ឋលេខាធិការ | ១៥៧.៥០០ | ១០៥.០០០ | ៧៨.៧៥០ | ៧៨.៧៥០ | ៤២០.០០០ |

មាត្រា ៣ ._ ចំពោះសមាជិក សមាជិកាពរាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការនៃក្រសួង រដ្ឋលេខាធិការដ្ឋានស្ថាប័នពាក់ព័ន្ធ និងទីប្រឹក្សានៃរាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយក រដ្ឋមន្ត្រី ព្រមទាំងមន្ត្រីស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការឡើងទៅ ដែលមានដំណែងពីរ ឬ បី មានសិទ្ធិទទួលប្រាក់បំណាច់ខាងលើបានតែមួយមុខតំណែង ក្នុងតំណែងណាមួយក៏បាន ។

មាត្រា ៤ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៧៨ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ ._ តែងតាំងលោក ឌុច សុន ជាប្រធាននាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាលវិជ្ជាជីវៈ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ។